**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**រដ្ឋបាលជលផល**

លេខ:......១៣១០......ជផ

# សេចក្ដីជូនដំណឹង
## ស្ដីពី
## រដូវបិទនេសាទ ឆ្នាំ២០១៥

- យោងព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ស្ដីពីការប្រកាសឱ្យប្រើច្បាប់ស្ដីពីជលផល

- ប្រកាសលេខ៤៥៨ ប្រក.កសកចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ ស្ដីពីការកែសម្រួលប្រកាសលេខ ១២៩ ប្រក.កសក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២ ស្ដីពីការកំណត់ប្រភេទឧបករណ៍នេសាទដែលអនុញ្ញាតឱ្យធ្វើនេសាទក្នុងដែននេសាទទឹកសាបនិងដែននេសាទសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជូនដំណឹងដល់សាធារណជន និងអ្នកនេសាទទាំងអស់ឱ្យបានជ្រាបថា រដូវបិទនេសាទសម្រាប់ការនេសាទនៅក្នុងដែននេសាទទឹកសាប ត្រូវបានកំណត់ដូចខាងក្រោម៖

- ចាប់ពីថ្ងៃទី០១ ខែមិថុនា ដល់ថ្ងៃទី៣០ ខែកញ្ញា ចំពោះដែននេសាទទឹកសាបដែលស្ថិតនៅខាងជើងខ្សែស្របទន្លេចតុម្មុខ ដែលរួមមានខេត្តទាំងអស់ជុំវិញបឹងទន្លេសាបនិងបណ្ដាខេត្ត កំពង់ចាម ត្បូងឃ្មុំ ក្រចេះ ស្ទឹងត្រែង រតនគីរី មណ្ឌលគីរី ព្រះវិហារ ប៉ៃលិន ឧត្ដរមានជ័យ និងរាជធានីភ្នំពេញ និងខេត្តកណ្ដាលផ្នែកខាងជើងចតុម្មុខ។

- ចាប់ពីថ្ងៃទី០១ ខែកក្កដា ដល់ថ្ងៃទី៣១ ខែតុលា ចំពោះដែននេសាទទឹកសាបដែលស្ថិតនៅខាងត្បូងខ្សែស្របទន្លេចតុម្មុខ ដែលរួមមាន រាជធានីភ្នំពេញផ្នែកខាងត្បូងចតុម្មុខ ខេត្តកណ្ដាល ព្រៃវែង តាកែវ កំពង់ស្ពឺ និងខេត្តស្វាយរៀង។

នៅក្នុងរយៈពេលបិទនេសាទនេះ អ្នកនេសាទទាំងអស់ត្រូវប្រើប្រាស់តែឧបករណ៍នេសាទគ្រួសារដែលមានចែងក្នុងប្រកាសលេខ៤៥៨ ប្រក.កសក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ ប៉ុណ្ណោះ។

ចំពោះឧបករណ៍ អួន ម៉ាញ់ ចៃវ៉ា ជន សាប នាម ឈ្នក់ មិនអនុញ្ញាតឲ្យប្រើឡើយក្នុងរដូវបិទនេសាទនេះ។ ដោយឡែក ឧបករណ៍នេសាទលបនិងសៃយ៉ុន អនុញ្ញាតឲ្យប្រើរបាំងព្រួលរួមផ្សំមិនលើសពី១០ ម៉ែត្រ ឬមិនលើសពី១/៣នៃទទឹងមុខទឹក រីឯឧបករណ៍មងអាចធ្វើនេសាទបានតែប្រវែង១០០ ម៉ែត្រ ប៉ុណ្ណោះ។

ម្យ៉ាងទៀត សូមបងប្អូនអ្នកនេសាទទាំងអស់អនុវត្តតាមអនុសាសន៍ទាំង៧ ចំណុច របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ឲ្យបានខ្ជាប់ខ្ជួន ជាពិសេសជួយការពារកន្លែងអភិរក្សជលផលឲ្យបានគង់វង្ស ដើម្បីទុករក្សាពូជត្រី។

រដ្ឋបាលជលផលសង្ឃឹមថា សាធារណជន និងអ្នកនេសាទទាំងអស់ នឹងអនុវត្តតាមសេចក្ដីជូនដំណឹងនេះ ដើម្បីចូលរួមចំណែកថែរក្សា និងការពារធនធានជលផលឲ្យបានគង់វង្ស សម្រាប់ប្រជាពលរដ្ឋខ្មែរយើងក្នុងជំនាន់នេះ ក៏ដូចជាជំនាន់ក្រោយៗទៀត។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៥

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

**អេង ជាសាន**

**ចម្លងជូន:**

-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

«ដើម្បីជូនជ្រាបជាព័ត៌មាន»

-គ្រប់សាលាខេត្ត-រាជធានី

«ដើម្បីជួយជំរុញការអនុវត្តឲ្យមានប្រសិទ្ធិភាព»

-គ្រប់អង្គភាពក្រោមឱវាទរដ្ឋបាលជលផល

«ដើម្បីចាត់វិធានការបង្ក្រាបបទល្មើសឲ្យបានតឹងរឹង និងមានប្រសិទ្ធិភាពបំផុត»

-ស្ថានីយ៍វិទ្យុនិងទូរទស្សន៍

«ដើម្បីជួយធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ»

-ឯកសារ កាលប្បវត្តិ

អាសយដ្ឋានៈអាគារលេខ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ប្រអប់សំបុត្រលេខ៥៨២ ☏/Fax: (855) 23 215 470 www.fia.gov.kh
Address #186 Preah Norodom Blvd., Sangkat Tonle Bassac, Khan Chamcar Mon, Phnom Penh capital, Cambodia. P.O.Box 582. ☏/Fax: (855) 23 215 470 www.fia.gov.kh